មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# កំណត់ត្រាសង្ខេប

# ការបំពេញកាតព្វកិច្ចរបស់កម្ពុជាចំពោះកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសក្នុងរយៈពេល ៣០ឆ្នាំ

## ខែតុលា ឆ្នាំ២០២១

## ខ្លឹមសារសង្ខេប

កាលពីបីទសវត្សរ៍មុន ប្រទេសកម្ពុជាបានឆ្លងផុតពីជម្លោះប្រដាប់អាវុធដែលអូសបន្លាយរយៈពេលជាច្រើនទសវត្សរ៍ ព្រមទាំងភាពចលាចលនយោបាយផ្ទៃក្នុង នៅពេលដែលប្រទេស បានចុះហត្ថលេខា និងអនុម័តកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស("កិច្ចព្រមព្រៀង")។ កិច្ចព្រមព្រៀងនេះបានកំណត់នូវព្រឹត្តិការណ៍ដ៏សំខាន់មួយនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ដោយកំណត់ប្រទេសកម្ពុជាជាប្រទេសដែលប្រកាន់នូវលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងគាំទ្រឱ្យសម្រេចបាននូវសន្តិភាព និងស្ថិរភាពយូរអង្វែង ដោយគោរពសិទ្ធិមនុស្ស។ ទោះជាយ៉ាងណាក៏ដោយ ទិដ្ឋភាពប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនាពេលបច្ចុប្បន្ន នៅក្នុងប្រទេសកម្ពុជាអាចត្រូវបានគេមើលឃើញថា ជាការបញ្ច្រាសនឹងគោលដៅអ្នកតាក់តែងកិច្ចព្រមព្រៀងដែលបានប្រមើលមើលកាលពី៣០ឆ្នាំមុន ហើយជាចំណោទអំពីការអនុលោមដាក់ស្តែងកន្លងមកនេះ។

ដើម្បីរម្លឹកដល់ខួប៣០ឆ្នាំនៃការអនុម័តកិច្ចព្រមព្រៀងនេះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ចេញផ្សាយកំណត់ត្រាសង្ខេបនេះ ដើម្បីពិនិត្យឡើងវិញអំពីការអនុវត្តរបស់កម្ពុជាចំពោះកិច្ចព្រមព្រៀង និងពិភាក្សាអំពីសារៈសំខាន់នៃព្រឹត្តិការណ៍ដែលកន្លងទៅសាមសិបឆ្នាំនេះ។ ជាដំបូង កំណត់ត្រាសង្ខេបនេះនឹងផ្តល់នូវទិដ្ឋភាពទូទៅនៃក្របខ័ណ្ឌដែលបង្កើតឡើងដោយកិច្ចព្រមព្រៀង ជាមួយនឹងកាតព្វកិច្ចដែលបានដាក់មកលើប្រទេសកម្ពុជា រដ្ឋហត្ថលេខី និងអង្គការសហប្រជាជាតិ ("អ.ស.ប")។ បន្ទាប់មក កំណត់ត្រាសង្ខេបនេះនឹងពិភាក្សាការអនុវត្ត ឬមិនអនុវត្តរបស់ប្រទេសកម្ពុជាទៅនឹងកិច្ចព្រមព្រៀង ព្រមជាមួយសារៈសំខាន់នៃខួប៣០ឆ្នាំ និងបញ្ចប់ដោយការផ្តល់អនុសាសន៍ដល់ភាគីពាក់ព័ន្ធនានា។

កំណត់ត្រាសង្ខេបនេះត្រូវចងក្រងឡើងដោយ ម.ស.ម.ក ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

**តើអ្វីទៅជាកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស?**

ប្រទេសកម្ពុជាមានប្រវត្តិសាស្ត្រជូរចត់ដោយសារតែជម្លោះដ៏យូរលង់ សង្គ្រាម ការកាន់កាប់ និងអំពើប្រល័យពូជសាសន៍។ បន្ទាប់ពីរបបខ្មែរក្រហម និងការកាន់កាប់របស់ប្រទេសវៀតណាម ភាគីជាច្រើនចង់បញ្ចប់ជម្លោះដែលនាំឱ្យមានការអនុម័តកិច្ចព្រមព្រៀងនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដែលជាបេសកកម្មដំបូងរបស់ អ.ស.ប ក្នុងការរក្សាសន្តិភាពបន្ទាប់ពីសម័យសង្គ្រាមត្រជាក់។[1] កិច្ចព្រមព្រៀងនេះមានឈ្មោះជាផ្លូវការថា កិច្ចព្រមព្រៀងសន្តិភាពស្តីពីដំណោះស្រាយនៅកម្ពុជា ដើម្បីបញ្ចប់ជម្លោះនៅកម្ពុ ហើយត្រូវបានចុះហត្ថលេខាដោយប្រទេសចំនួន១៩។[2]

## <u>មូលដ្ឋានគ្រឹះនៃកិច្ចព្រមព្រៀង</u>

កិច្ចព្រមព្រៀងនេះមានសារសំខាន់សម្រាប់ប្រទេសកម្ពុជា ព្រោះមិនត្រឹមតែផ្តល់ឱ្យប្រទេស និងប្រជាជនកម្ពុជាដែលត្រូវការឯករាជ្យភាព បន្ទាប់ពីការដាក់អាណានិគមអស់រយៈពេលមួយរយឆ្នាំ ហើយបន្តដោយជម្លោះ និងការគ្រប់គ្រងរាប់ទសវត្សរ៍នោះទេ ប៉ុន្តែដោយសារតែកិច្ចព្រមព្រៀងនេះធានាថាសិទ្ធិស្វ័យសម្រេចសម្រាប់ពលរដ្ឋកម្ពុជាមានសារៈសំខាន់បំផុត។ កិច្ចព្រមព្រៀងបង្កើតជាបណ្តុំគតិយុត្តិមានលក្ខណៈទូលំទូលាយមួយ ដែលរួមបញ្ចូលឯកសារដាច់ដោយឡែកពីគ្នាចំនួន ៤ ដែលមានឋានៈផ្លូវច្បាប់ផ្សេងៗគ្នា[3] រួមមានកិច្ចព្រមព្រៀងចុងក្រោយនៃសន្និសិទប៉ារីសស្តីពីកម្ពុជាដែលពិពណ៌នាលម្អិតអំពីដំណាក់កាលក្នុងការបញ្ចប់កិច្ចព្រមព្រៀងនិងការចុះហត្ថលេខា សេចក្តីថ្លែងការណ៍មួយស្តីពីការស្តារ និងការកសាងប្រទេសកម្ពុជាឡើងវិញដែលជាមូលដ្ឋានគ្រឹះនៃលក្ខខណ្ឌក្នុងការចងកិច្ចព្រមព្រៀង និងសន្ធិសញ្ញាអន្តរជាតិដែលចងកាតព្វកិច្ចផ្លូវច្បាប់ចំនួន២គឺ កិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា (ACPS) និងកិច្ចព្រមព្រៀងស្តីពីអធិបតេយ្យភាព ឯករាជ្យ បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រឹតភាព ឯកភាពជាតិកម្ពុជា (ASIT)។ ឯកសារទាំងនេះបានចែងថា ត្រូវ

---

[1] Laura McGrew and Scott Worden, 'Lessons from Cambodia's Paris Peace Accords for Political Unrest Today' (United States Institute of Peace, 16 May 2017).

[2] CCHR, Briefing Note: Democracy Under Threat 2016: Fulfilling the Promise of the Paris Agreements, 25 Years On' (CCHR, September 2016); States parties to the Agreements excluding Cambodia: Australia, Brunei Darussalam, Canada, China, France, India, Indonesia, Japan, Laos, Malaysia, Philippines, Singapore, Thailand, USSR, United Kingdom, USA, Vietnam and the former Yugoslavia.

[3] UN General Assembly and Security Council, The Paris Conference on Cambodia, A/46/608, S/23177 (30 October 1991).

ចូលជាធរមានបន្ទាប់ពីចុះហត្ថលេខា ហើយថែមកំណត់អំពីកាតព្វកិច្ចធំៗ[4] ដូចជាកាតព្វកិច្ចរបស់កម្ពុជា របស់រដ្ឋដែលជាភាគីហត្ថលេខី និងរបស់ស្ថាប័នផ្សេងៗរបស់អង្គការសហប្រជាជាតិ។ បន្ថែមពីនេះ មាត្រា ២៨ (១) នៃកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា បានដាក់កាតព្វកិច្ចជាក់លាក់មួយចំនួនលើភាគីហត្ថលេខីទាំងអស់ដូចជា ការបញ្ជាក់ឡើងវិញនូវកាតព្វកិច្ចទូទៅក្រោមច្បាប់អន្តរជាតិក្នុងការ *«ធ្វើតាមដោយស្មោះស្ម័គ្រនូវរាល់កាតព្វកិច្ចដែលបានសន្យា»* និងក្នុងការ *«ធ្វើសហប្រតិបត្តិការពេញលេញជាមួយអង្គការសហប្រជាជាតិ»*។

ខណៈដែលផ្នែកទី១នៃកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជាចែងយ៉ាងច្បាស់ទាក់ទងនឹងការរៀបចំសម្រាប់រយៈពេលអន្តរកាល ចាប់ពីថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ ដល់ខែកញ្ញា ឆ្នាំ១៩៩៣[5] កាតព្វកិច្ចទាំងអស់ពាក់ព័ន្ធនឹងសិទ្ធិមនុស្សស្ថិតនៅក្នុងផ្នែកទី២ នៃកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា ឬនៅក្នុងកិច្ចព្រមព្រៀងទាក់ទិននឹងអធិបតេយ្យភាព ឯករាជ្យភាព បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រឹតភាព ឯកភាពជាតិកម្ពុជា ពុំមានចែងពីការកំណត់ពេលវេលាឡើយ។ ដូច្នោះ ការសន្យាទាំងអស់លើកឡើងខាងក្រោមនៅតែជាប់កាតព្វកិច្ចលើបណ្ដាភាគីហត្ថលេខី។

## <u>ភាគីពាក់ព័ន្ធនឹងកិច្ចព្រមព្រៀង និងតួនាទីរបស់ពួកគេ</u>

កិច្ចព្រមព្រៀងនេះបានប្រគល់កាតព្វកិច្ចជាច្រើនដល់ប្រទេសហត្ថលេខីរបស់ខ្លួនដែលជាគោលបំណងសំខាន់នៃកិច្ចព្រមព្រៀងទាំងនេះគឺដើម្បី *«ធានាឱ្យប្រជាជនកម្ពុជាប្រើប្រាស់សិទ្ធិស្វ័យសម្រេចតាមរយៈការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ»*[6]។ ដើម្បីបង្ហាញការប្តេជ្ញាចិត្តរយៈពេលវែងសម្រាប់ប្រជាជនកម្ពុជា ចាំបាច់ក្នុងការបង្កើតឱ្យមានតុល្យភាពរវាងអង្គការសហប្រជាជាតិ ប្រទេសកម្ពុជា និងប្រទេសហត្ថលេខី។

*កាតព្វកិច្ចរបស់កម្ពុជា*

---

[4] The Agreements were signed on behalf of Cambodia by the newly-formed Supreme National Council of Cambodia, comprising representatives of the various factions in the Cambodian conflict, and deemed by the Agreements a legitimate source of authority Article 28(2) ACPS explicitly states the SNC's signature committed "all Cambodian parties and armed forces." It should therefore be considered that the SNC was competent to engage the responsibility of the state of Cambodia under international law.

[5] ACPS, Article 1.

[6] ACPS, Preamble, para. 2.

កិច្ចព្រមព្រៀងទីក្រុងប៉ារីសបង្កើតជាមូលដ្ឋានគ្រឹះមួយសម្រាប់ដំណោះស្រាយនយោបាយថ្មីមួយនៅកម្ពុជាដែលមានឫសគល់ផ្អែកសិទ្ធិមនុស្ស និងចងភ្ជាប់ដោយមិនអាចបំបែកបានទៅនឹងក្របខណ្ឌច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលមានវត្តមានរួចទៅហើយនៅឆ្នាំ១៩៩១។ នៅក្នុងកិច្ចព្រមព្រៀង កម្ពុជាក៏ប្តេជ្ញាចិត្តធ្វើតាមប្រព័ន្ធនយោបាយជាក់លាក់មួយ ដែលកំណត់ដោយលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។ ប្រព័ន្ធបែបនេះមិនត្រឹមតែត្រូវការកម្រិតអប្បបរមានៃការគោរពសិទ្ធិ និងសេរីភាពបុគ្គលនៅកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវការការលើកកម្ពស់យ៉ាងសកម្មនូវបរិយាកាសដែលលទ្ធិប្រជាធិបតេយ្យពហុបក្សអាចរីកលូតលាស់បាន។ នៅពេលដែលចុះហត្ថលេខាលើកិច្ចព្រមព្រៀង កម្ពុជាប្តេជ្ញាក្នុងការលើកកម្ពស់សិទ្ធិ និងសេរីភាពទាំងអស់ដែលមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងលិខិតុបករណ៍សិទ្ធិមនុស្សពាក់ព័ន្ធផ្សេងទៀត។[7]

| កាតព្វកិច្ចជាក់លាក់ |
|---|
| **មាត្រា១២ និងឧបសម្ព័ន្ធ៤ និងឧបសម្ព័ន្ធ៥ នៃកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា៖ សិទ្ធិក្នុងការបោះឆ្នោតដោយសេរី និងត្រឹមត្រូវ** |
| **មាត្រា១៥ (២) នៃកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា ផ្តល់កាតព្វកិច្ចដូចខាងក្រោមដល់រដ្ឋាភិបាលកម្ពុជាក្នុងការ៖**<br>- ធានាគោរព និងប្រតិបត្តិតាមសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននៅកម្ពុជា<br>- គាំទ្រសិទ្ធិរបស់ពលរដ្ឋកម្ពុជាទាំងអស់ ក្នុងការធ្វើសកម្មភាពដែលជំរុញ និងការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន<br>- ចាត់បណ្តាវិធានការដ៏មានប្រសិទ្ធភាពដើម្បីធានាថានយោបាយ និងអំពើប្រព្រឹត្តនៅក្នុងអតីតកាល មិនត្រូវបានអនុញ្ញាតឱ្យវិលត្រឡប់មកវិញជាច់ខាត និង<br>- ចូលរួមគោរពតាមកិច្ចព្រមព្រៀងអន្តរជាតិទាំងឡាយដែលពាក់ព័ន្ធដល់សិទ្ធិមនុស្ស |

តាមមាត្រា២៣ និងឧបសម្ព័ន្ធទី៥ នៃ *«គោលការណ៍សម្រាប់រដ្ឋធម្មនុញ្ញថ្មីមួយរបស់កម្ពុជា»* រដ្ឋធម្មនុញ្ញកម្ពុជាត្រូវតែចែងអំពីសិទ្ធិមនុស្ស សេរីភាពមូលដ្ឋាន និងដាក់បញ្ចូលលក្ខន្តិកៈរបស់កម្ពុជាជាប្រទេសអព្យាក្រឹត។ ស្របពេលដែលរដ្ឋធម្មនុញ្ញកម្ពុជាបានចែងអំពីសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋានជាច្រើនដើម្បីការពារប្រជាពលរដ្ឋរបស់ខ្លួន និងបានពង្រឹងឋានៈប្រទេសកម្ពុជាជាប្រទេសប្រជាធិបតេយ្យសេរី

[7] ACPS art. 15(1) & ASIT art. 3.

ការអនុវត្តរដ្ឋធម្មនុញ្ញនេះខុសពីកាតព្វកិច្ចរបស់កម្ពុជាក្រោមកិច្ចព្រមព្រៀង (ធ្វើការពិភាក្សានៅផ្នែកខាងក្រោម)។ ខាងក្រោមនេះគឺជាខ្លឹមសារសំខាន់ៗអំពីសិទ្ធិដែលរដ្ឋធម្មនុញ្ញកម្ពុជាត្រូវតែការពារ៖

| កាតព្វកិច្ចជាក់លាក់ |
|---|
| សិទ្ធរស់រានមានជីវិត សេរីភាពផ្ទាល់ខ្លួន សន្តិសុខ និងសេរីភាពក្នុងការដើរហើរ |
| សេរីភាពខាងជំនឿសាសនា |
| សេរីភាពខាងការបញ្ចេញមតិ |
| សេរីភាពខាងការជួបប្រជុំ |
| សេរីភាពខាងសមាគម រួមបញ្ចូលទាំងគណបក្សនយោបាយ និងសហជីព |
| ដំណើរការត្រឹមត្រូវ និងសមភាពចំពោះមុខច្បាប់ |
| ការការពារពីការដកហូតទ្រព្យសម្បត្តិដោយបំពាន ឬការដកហូតទ្រព្យសម្បត្តិដោយគ្មានសំណងសមរម្យ |
| សេរីភាពរួចផុតពីការរើសអើងពូជសាសន៍ ជនជាតិ ជំនឿសាសនា ឬភេទ |
| ប្រទេសកម្ពុជាក្លាយជាប្រទេសប្រជាធិបតេយ្យផ្អែកលើពហុនិយម |
| ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ ត្រូវធ្វើឡើងជាមួយនឹងសិទ្ធិក្នុងការបោះឆ្នោត និងការបោះឆ្នោតជាសកល |
| ប្រព័ន្ធតុលាការឯករាជ្យ |

*កាតព្វកិច្ចរបស់ប្រទេសហត្ថលេខីផ្សេងទៀត*

អមជាមួយនឹងការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការគោរពសិទ្ធិមនុស្សតាមមាត្រា ១៥(២)(ខ) នៃកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា និងមាត្រា៣(២)(ខ) នៃកិច្ចព្រមព្រៀងស្តីពីអធិបតេយ្យភាព ឯករាជ្យភាព បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រឹតភាព ឯកភាពជាតិកម្ពុជា ចែងថា៖ ប្រទេសហត្ថលេខីផ្សេងៗទៀតនៃកិច្ចព្រមព្រៀងនេះសន្យាថាជួយ *«ជំរុញ និងលើកទឹកចិត្តដល់ការគោរពនិងប្រតិបត្តិតាមសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននៅកម្ពុជា»* ដូចដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងសិទ្ធិមនុស្សអន្តរជាតិទាំងឡាយ ឬក្នុងសេចក្តីសម្រេចទាំងឡាយរបស់ អ.ស.ប។ កាតព្វកិច្ចទាំងនេះត្រូវបានគាំទ្រដោយមាត្រា ៥(៤) នៃកិច្ចព្រមព្រៀងស្តីពីអធិបតេយ្យភាព ឯករាជ្យភាព បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រឹតភាព ឯកភាពជាតិកម្ពុជា ដែលទាមទារឱ្យប្រទេសហត្ថលេខីក្នុងការ *«ស្នើរដល់អង្គការមានសមត្ថកិច្ចរបស់អង្គការសហប្រជាជាតិ»* ឱ្យចាត់វិធានការផ្លូវច្បាប់សមស្របក្នុងករណីដែលមានការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ដើម្បីទប់ស្កាត់និងការ

លុបបំបាត់ការរំលោភបែបនេះ។ បន្ថែមលើសពីនេះ មាត្រា២៩ នៃកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជាចែងថា ក្នុងករណីដែលកិច្ចព្រមព្រៀងរងការរំលោភ ឬគំរាមកំហែងនឹងមានការរំលោភ សហប្រធានទាំងពីរនៃសន្និសិទប៉ារីសស្តីពីកម្ពុជា [បារាំង និងឥណ្ឌូនេស៊ី] តាមរយៈការស្នើរសុំរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ *«នឹងត្រូវធ្វើការពិគ្រោះគ្នាដ៏សមស្របនានា»* រាប់ទាំងជាមួយសមាជិកសន្និសិទក្រុងប៉ារីស ដើម្បីដោះស្រាយការរំលោភបំពាន និងធានាដល់ការគោរពកិច្ចព្រមព្រៀងនេះ។

## *កាតព្វកិច្ចរបស់អង្គការសហប្រជាជាតិ*

មួយផ្នែកធំនៃកិច្ចព្រមព្រៀងទាំងនេះ មានពាក់ព័ន្ធទៅនឹងអាណត្តិការងាររបស់អាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិនៅកម្ពុជា «អ៊ុនតាក់» ដែលបង្កើតឡើងតាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិលេខ ៧៤៥ ក្នុងឆ្នាំ១៩៩២។ ក្នុងអំឡុងពេលអន្តរកាល អ៊ុនតាក់ទទួលខុសត្រូវក្នុងការសម្រួលឱ្យមានបរិយាកាសមួយប្រសើរដើម្បីធានាដល់ការគោរពសិទ្ធិមនុស្សដូចមានចែងក្នុងមាត្រា១៦ នៃកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា។ ទោះជាយ៉ាងណា មាត្រា១៧ នៃកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា និងមាត្រា៣(៣) នៃកិច្ចព្រមព្រៀងស្តីពីអធិបតេយ្យភាព ឯករាជ្យភាព បូរណភាព និងភាពមិនអាចរំលោភបាននៃដែនដី អព្យាក្រឹតភាព ឯកភាពជាតិកម្ពុជា ចែងថា បន្ទាប់ពីដំណាក់កាលអន្តរកាល គណៈកម្មការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ដែលបច្ចុប្បន្នប្តូរមកជាក្រុមប្រឹក្សាសិទ្ធិមនុស្ស ("ក.ប.ស") គប្បីបន្តតាមដានឱ្យបានដិតដល់ពីស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា ហើយបើចាំបាច់គួរតែងតាំងអ្នករាយការណ៍ពិសេសម្នាក់។ ក.ប.ស បន្តកាតព្វកិច្ចតាមដានបញ្ហាសិទ្ធិមនុស្សនៅកម្ពុជា និងធ្វើការតាមដានតាមរយៈយន្តការពិនិត្យជាសកលតាមពេលវេលាកំណត់[8] ក៏ដូចជាតាមរយៈការតែងតាំងអ្នករាយការណ៍ពិសេសពាក់ព័ន្ធនឹងស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា[9]។

## <u>សារៈសំខាន់នៃកិច្ចព្រមព្រៀង</u>

ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងនេះបានកំណត់នូវព្រឹត្តិការណ៍ដ៏សំខាន់មួយសម្រាប់ជាផ្លូវឆ្ពោះទៅរកភាពស្វ័យសម្រេចសម្រាប់ប្រទេសកម្ពុជា ក៏ដូចជាការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងនយោបាយរបស់ខ្លួនក្នុងនាមជាប្រទេសមួយ។ កិច្ចព្រមព្រៀងនេះបានផ្តល់នូវមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់នីតិរដ្ឋតាមរ

[8] UN General Assembly, Resolution, A/RES/60/251 (3 April 2006).

[9] UN Office of the High Commissioner of Human Rights, Situation on human rights in Cambodia, E/CN.4/RES/1933/6 (19 February 1993).

យៈការតាក់តែង និងអនុម័តរដ្ឋធម្មនុញ្ញ និងបានបង្កើតបរិយាកាសសម្រាប់លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្សដ៏រឹងមាំ។ អ្វីដែលសំខាន់បំផុតនោះ កិច្ចព្រមព្រៀងបាននាំមកនូវសន្តិភាព និងស្ថេរភាពដែលចាំបាច់ដល់ប្រទេសកម្ពុជាដើម្បីធ្វើឱ្យសិទ្ធិមនុស្សមានការរីកចម្រើន។

## សារៈសំខាន់និងភាពពាក់ព័ន្ធនៅខួបគម្រប់ ៣០ ឆ្នាំ

បីទសវត្សរ៍ក្រោយមក ចាប់តាំងពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះកម្ពុជាសម្រេចបាននូវព្រឹត្តិការណ៍សំខាន់ៗក្នុងការអភិវឌ្ឍន៍របស់ខ្លួនក្នុងនាមជាប្រទេសមួយ។ កម្ពុជាបានងើបឡើងពីអតីតកាលដ៏អាក្រក់របស់ខ្លួន ហើយបានរក្សាការរំដោះខ្លួនពីជម្លោះប្រដាប់អាវុធនិងជម្លោះផ្ទៃក្នុង។ តាមស្មារតីនៃកិច្ចព្រមព្រៀងប្រទេសកម្ពុជាពិតជាបានសម្រេចនូវ" សន្តិភាពអវិជ្ជមាន" ដោយអវត្តមាននៃសង្គ្រាមនិងជម្លោះប្រដាប់អាវុធផ្ទៃក្នុង។ ទោះយ៉ាងណាការសម្រេចបាននូវសន្តិភាព គឺត្រូវមានលើសពីអវត្តមាននៃសង្គ្រាមទៀត ដោយត្រូវតែរួមបញ្ចូលសង្គមមួយដែលយុត្តិធម៌សង្គម សមភាព ការគោរពសិទ្ធិមនុស្សនិងស្ថាប័នប្រជាធិបតេយ្យរឹងមាំត្រូវបានគោរពនិងមានភាពរីកចម្រើនៈ" សន្តិភាពវិជ្ជមាន"[10] ។ បើគ្មានសន្តិភាពវិជ្ជមានទេ សន្តិភាពពិតប្រាកដមិនអាចសម្រេចបានដោយពេញលេញនៅក្នុងប្រទេសឡើយ។ ថ្វីត្បិតតែកម្ពុជាសម្រេចបាននូវសន្តិភាពអវិជ្ជមានក្តី ប៉ុន្តែសន្តិភាពជាវិជ្ជមានសម្រាប់ប្រទេសនេះហាក់បីដូចជានៅតែជាគោលដៅវែងឆ្ងាយ ដូចជាប៉ុន្មានឆ្នាំកន្លងមកនេះ ការគោរពនិងការការពារសិទ្ធិមនុស្សបានធ្លាក់ចុះយ៉ាងខ្លាំងហើយមិនមានសញ្ញានាំឱ្យមានភាពល្អប្រសើរឡើងវិញឡើយ។ យោងតាមស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជានេះ មិនត្រឹមតែជាចំណោទអំពីអនាគតនៃលទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសនោះទេតែក៏ជាចំណោទជាច្រើនថាតើកិច្ចព្រមព្រៀងត្រូវបានគោរព ត្រឹមត្រូវហើយឬនៅ ឬគ្រាន់តែប្រើជាស្បែដើម្បីបន្លំប្រជាធិបតេយ្យ។

### <u>សមិទ្ធិផលដែលកើតមានឡើងទៅតាមស្មារតីនៃកិច្ចព្រមព្រៀង</u>

បន្ទាប់ពីការអនុម័តកិច្ចព្រមព្រៀងនេះ កម្ពុជាខ្វះនៅមានការប្រឈមផ្នែកស្ថាប័ននិងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានដែលជួយការពារសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន[11]។ ថ្វីបើមានឧបសគ្គទាំងនេះក៏ដោយកិច្ចព្រមព្រៀងបាននាំមកនូវការអភិវឌ្ឍន៍វិជ្ជមានជាច្រើនសម្រាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមរបស់កម្ពុជា។

---

[10] Chak Sopheap, ''An all-time low': Cambodia's search for peace and democracy continues' (*Southeast Asia Globe*, 15 September 2020)

[11] UNTAC, 'Human Rights Component Final Report' (UNTAC, September 1993), p. 1.

អំឡុងប៉ុន្មានឆ្នាំដំបូងបន្ទាប់ពីការអនុម័តកិច្ចព្រមព្រៀង នៅមានការប្រឈមដោយសារតែភាគីខ្មែរក្រហម[12]បដិសេធចូលរួមក្នុងដំណើរការដកហូតអាវុធ ដែលបណ្តាលឱ្យមានការមិនទុកចិត្តភ្លាមៗ ពីភាគីកម្ពុជាដទៃទៀត ចំពោះកិច្ចព្រមព្រៀង ដែលបន្ទាប់មកបានប្រឆាំងនឹងការដកហូតអាវុធដោយខ្លាចមានជម្លោះប្រដាប់អាវុធកើតឡើង[13]។ ការវិវត្តនៃការដកហូតអាវុធនិងការរំសាយយោធាបានបន្តជាប់គាំងទោះបីជាការបោះឆ្នោតប្រជាធិបតេយ្យលើកដំបូងនៅ ឆ្នាំ១៩៩៣ ត្រូវបានរៀបចំហើយក៏ដោយ។ ដូច្នេះរដ្ឋាភិបាលកម្ពុជា( រដ្ឋាភិបាលកម្ពុជា )[14]បានអនុម័ត*ច្បាប់ស្តីពីការហាមឃាត់ក្រុមកម្ពុជាប្រជាធិបតេយ្យ* ដែលបានសន្យាលើកលែងទោសដល់កងទ័ពក្នុងរបបខ្មែរក្រហមដែលបានរត់គៀសខ្លួនជាពិសេសពួកគេត្រូវបានផ្តល់ជូននូវសន្តិសុខការការពារសិទ្ធិលើទ្រព្យសម្បត្តិ និងការសមាហរនកម្មផ្តល់ជំនួយនិងការគាំពារ ។ កម្មវិធីនេះទទួលបានប្រសិទ្ធិភាពនាំឱ្យសមាជិកខ្មែរក្រហមចំនួន ៧.០០០ នាក់បានចុះចូលក្នុងរយៈពេលប្រាំមួយខែ[15]។ លើសពីនេះកម្មវិធីជំនួយអតីតយុទ្ធជនកម្ពុជាត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៩ និងបានផ្តល់ជំនួយដល់អតីតទាហានក្នុងការប៉ុនប៉ងធ្វើឱ្យរំសាយកងទ័ព[16]។ នៅឆ្នាំ ១៩៩៨ ខ្មែរក្រហមបានចុះចាញ់[17]ជាផ្លូវការ ហើយរដ្ឋាភិបាលបានបង្កើតកម្មវិធីដកហូតអាវុធខ្នាតតូចដោយមានជំនួយពីអឺរ៉ុបក្នុងការទប់ស្កាត់អាវុធធុនតូច និងអាវុធធុនស្រាលនៅកម្ពុជាដែលកាត់បន្ថយយ៉ាងច្រើននូវចំនួនអាវុធធុនតូចដែលកំពុងចរាចរនៅក្នុងប្រទេសកម្ពុជា[18]។ តាមរយៈយុទ្ធសាស្ត្រទាំងនេះនិងការដឹកនាំដោយក្រុមចម្រុះប្រទេសកម្ពុជាអាចទទួលបានជោគជ័យគួរឱ្យកត់សម្គាល់ ក្នុងការនាំមកនូវស្ថិរភាពដល់ប្រទេសតាមរយៈការបញ្ចប់ជម្លោះ ដែលអូសបន្លាយពេលយូរដែលនាំឱ្យមានការបង្រួបបង្រួមជាតិ[19]។

ការដកហូតអាវុធ និងការសម្រេចបាននូវសន្តិភាពអវិជ្ជមាននៅក្នុងប្រទេសអនុញ្ញាតឱ្យមានការអភិវឌ្ឍន៍ សេដ្ឋកិច្ចនិងវិបុលភាពយ៉ាងឆាប់រហ័ស។ ប្រទេសកម្ពុជាគឺជាប្រទេសដែលមានកំណើនសេដ្ឋកិច្ចលឿនបំផុតនៅលើពិភពលោកជាមួយនឹងអត្រាកំណើនសេដ្ឋកិច្ចជាមធ្យម ៧.៧ ភាគរយពីឆ្នាំ ១៩៩៨

---

12 At the time named the Party of Democratic Kampuchea.

13 Jianwei Wang, et al, ‘Disarmament and Conflict Resolution Project: Managing Arms In Peace Processes: Cambodia’ (United Nations Institute for Disarmament Research) UNIDIR/96/17 (1996) p. 21.

14 At the time, the RGC comprised of a coalition government with Prince Ranariddh and Prime Minister Hun Sen.

15 Peter Bartu and Neil Wilford, ‘Research Brief: Transitional Justice and DDR” The Case of Cambodia’ (*International Center for Transitional Justice*, June 2009).

16 This program was initially conducted by the RGC with the help of the World Bank in 1995/1996 but was not initially successful. The program was revamped in 1999 with slightly more success.

17 Luke Hunt, ‘The Truth About War and Peace in Cambodia: Some reading of the country’s history can be deceiving’ (*The Diplomat*, 5 January 2019).

18 Tiphaine Ferry, ‘How Disarmament, Demobilization and Reintegration Programs Could Have Facilitated the Establishment of Long-term Conflict Prevention in Post-Conflict Cambodia’ The Cambodia Law and Policy Journal Vol. 3. 129 – 155, 141.

19 Jianwei Wang, et al, ‘Disarmament and Conflict Resolution Project: Managing Arms In Peace Processes: Cambodia’ (United Nations Institute for Disarmament Research) UNIDIR/96/17 (1996) p. 21.

ដល់ឆ្នាំ២០១៩។ ជាលទ្ធផលនៃកំណើនសេដ្ឋកិច្ចឆាប់រហ័សនេះ នាំឱ្យធនាគារពិភពលោកប្រកាសថាកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥[20] ។ យ៉ាងណាក្តី សន្ទុះនៃការរីកចម្រើននេះក៏នាំមកនូវចំណោទអំពីនិរន្តរភាព និងតម្លាភាពផងដែរ ដែលមានការប្រឈមផ្នែកសិទ្ធិការងារ ការរំលោភសិទ្ធិដីធ្លីរួមទាំងការបណ្តេញចេញដោយបង្ខំ ដើម្បីបង្កើតផ្លូវសម្រាប់ការអភិវឌ្ឍន៍ដីឯកជនខ្នាតធំជាដើម។

ក្រៅពីសម្រេចបាននូវសន្តិភាពអវិជ្ជមាន ស្ថិរភាពនិងការអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជាក៏បានបំពេញកាតព្វកិច្ចមួយចំនួនរបស់ខ្លួន ក្រោមកិច្ចព្រមព្រៀងដើម្បីលើកកម្ពស់សិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានដូចជាការទទួលបានយុត្តិធម៌និងសមភាព។ រដ្ឋាភិបាលកម្ពុជា បានចូលរួមជាប្រចាំជាមួយយន្តការរបស់អង្គការសហប្រជាជាតិរួមមានការពិនិត្យឡើងវិញ របស់គណៈកម្មាធិការសិទ្ធិមនុស្សអំពីការអនុលោមរបស់កម្ពុជាជាមួយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ (ICCPR) ក៏ដូចជាការពិនិត្យឡើងវិញតាមកាលកំណត់ជាសកល(UPR)ដែលរដ្ឋាភិបាលកម្ពុជាប្តេជ្ញាក្នុងការកែលម្អស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។

### *ការទទួលបានយុត្តិធម៌*

ចាប់តាំងពីការអនុម័តលើកិច្ចព្រមព្រៀងនេះ តុលាការភាគច្រើន គឺឋិតនៅទីក្រុងភ្នំពេញ មានន័យថាការទទួលបានយុត្តិធម៌គឺមិនមានសម្រាប់អ្នកដែលរស់នៅក្រៅទីក្រុងភ្នំពេញ ឬមិនអាចចូលដំណើរការបានដោយសារការធ្វើដំណើរថ្លៃនិងថ្លៃរដ្ឋបាលផ្សេងទៀត។ ទោះយ៉ាងណា នៅឆ្នាំ ២០២០ រដ្ឋាភិបាលកម្ពុជា បានបង្កើតសាលាឧទ្ធរណ៍ថ្នាក់តំបន់ចំនួន ៣ នៅខេត្តបាត់ដំបង ត្បូងឃ្មុំនិងព្រះសីហនុ ដែលអនុញ្ញាតឱ្យមានការទទួលបាននៃនីតិវិធីតុលាការកាន់តែច្រើនដល់អ្នកដែលនៅផ្នែកផ្សេងទៀតនៃប្រទេស[21]។ សមិទ្ធផលផ្សេងទៀតនៅក្នុងវិស័យនៃការទទួលបានយុត្តិធម៌រួមមានការបង្កើនការផ្តល់ជំនួយនិងសេវាកម្មផ្នែកច្បាប់ដោយឥតគិតថ្លៃដល់ជនក្រីក្រដែលត្រូវបានរាយការណ៍ថាបានគ្របដណ្តប់ប្រហែល ៥.០០០ ករណី[22] ការបង្កើតខ្សែទូរស័ព្ទពិគ្រោះយោបល់ផ្លូវច្បាប់ដោយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាសម្រាប់អ្នកមានប្រាក់ចំណូលទាប[23] និងការបង្កើតការិយាល័យច្បាប់នៅក្នុងពន្ធនាគារខេត្តទាំង ២៥ ដែលនឹងអនុញ្ញាតឱ្យមេធាវីមានការពិគ្រោះយោបល់ជាមួយកូនក្តីជាសម្ងាត់[24]។ នៅខែឧសភាឆ្នាំ

---

[20] The World Bank, 'The World Bank in Cambodia' (11 October 2021) https://www.worldbank.org/en/country/cambodia/overview#1.

[21] Vuon Dara, 'Regional appeal courts set in motion' (*Phnom Penh Post*, 4 March 2020).

[22] Voun Dara, 'BAKC represents poor in nearly 5,000 cases' (*Phnom Penh Post*, 11 November 2020).

[23] Soth Koemsoeun, 'Human rights committee's legal hotline receives praise' (*Phnom Penh Post*, 4 December 2019).

[24] Kim Sarom, 'Bar association builds room for lawyer, client consultation' (*Phnom Penh Post*, 21 May 2020).

២០២០ រដ្ឋាភិបាលកម្ពុជា បានបើកយុទ្ធនាការបោសសំអាតសំណុំរឿងផ្លូវច្បាប់នៅទូទាំងប្រទេសកម្ពុជាក្នុងគោលបំណងកាត់បន្ថយការកកស្ទះពន្ធនាគារ។ គិតត្រឹមថ្ងៃទី ៣១ ខែធ្នូឆ្នាំ ២០២០ ក្រសួងយុត្តិធម៌បានរាយការណ៍ថាបានដោះស្រាយ ៩៥% នៃសំណុំរឿងព្រហ្មទណ្ឌដែលនៅសេសសល់និង ៧៣% នៃសំណុំរឿងព្រហ្មទណ្ឌថ្មីសរុបប្រមាណ ៣៥.១០០ ករណី[25]។ យុទ្ធនាការនេះបច្ចុប្បន្នត្រូវបានបន្តរហូតដល់ថ្ងៃទី១៧ ខែឧសភាឆ្នាំ ២០២១ ។ លើសពីនេះទៀតនៅក្នុងខែកុម្ភៈ ឆ្នាំ២០២១ គណៈមេធាវីកម្ពុជាបានបង្ហាញពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការពង្រីកវិសាលភាពនៃការការពារនិងជំនួយផ្នែកច្បាប់ដល់សហគមន៍ក្រីក្រដោយបញ្ជាក់ពីតម្រូវការយុត្តិធម៌សង្គម[26]។

*សមភាព*

រដ្ឋាភិបាលក៏បានចាត់វិធានការដើម្បីកាត់បន្ថយវិសមភាពនៅក្នុងសង្គមកម្ពុជា។ គួរកត់សម្គាល់ថានៅឆ្នាំ២០២០ ក្រសួងកិច្ចការនារីបានចុះហត្ថលេខាលើផែនការយុទ្ធសាស្ត្រយេនឌ័ររយៈពេល ៥ឆ្នាំ ថ្មីគឺនារីរតនៈ ៥ ដើម្បីជួយលើកកម្ពស់សមភាពយេនឌ័រនៅគ្រប់វិស័យក្នុងសង្គមកម្ពុជានិងផែនការសកម្មភាពជាតិទប់ស្កាត់អំពើហិង្សាលើស្ត្រីសម្រាប់ឆ្នាំ ២០១៩-២០២៣[27] ។ ក្នុងទិវាសិទ្ធិនារីអន្តរជាតិនៅខែមីនាឆ្នាំ ២០២១ នាយករដ្ឋមន្ត្រីបានជំរុញឱ្យស្ថាប័នពាក់ព័ន្ធបន្តការពារនិងលើកកម្ពស់សិទ្ធិស្ត្រីដើម្បីលើកទឹកចិត្តពួកគេឱ្យក្លាយជាអ្នកដឹកនាំនិងចូលរួមកាន់តែច្រើនក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត[28]។

សកម្មភាពផ្សេងទៀតត្រូវបានអនុវត្តផងដែរ ដើម្បីលើកកម្ពស់សិទ្ធិស្ត្រីស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ភេទដូចគ្នា និងអ្នកប្តូរភេទ (LGBTIQ) នៅក្នុងប្រទេសកម្ពុជា។ បច្ចុប្បន្នច្បាប់នៅកម្ពុជាខកខានក្នុងការទទួលស្គាល់យេនឌ័រស្របច្បាប់ជាសកលដល់ពលរដ្ឋប្តូរភេទ សមភាពអាពាហ៍ពិពាហ៍សម្រាប់គូស្វាមីភរិយាអ្នកស្រឡាញ់ភេទដូចគ្នា ឬច្បាប់ប្រឆាំងការរើសអើងដែលការពារសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាជាពិសេស[29]។ បន្ទាប់ពីការត្រួតពិនិត្យ UPR របស់កម្ពុជានៅឆ្នាំ២០១៩ រដ្ឋាភិបាលបានប្តេជ្ញាទទួលយកអនុសាសន៍ចំនួនប្រាំបួន ដើម្បីអនុម័តច្បាប់មិនរើសអើង និងច្បាប់ផ្តល់សិទ្ធិអាពាហ៍ពិពាហ៍ស្មើភាពគ្នា និងការទទួលស្គាល់យេនឌ័រស្របច្បាប់[30]។ ដូចគ្នាផងដែរនៅឆ្នាំ២០១៩ រដ្ឋាភិបាលកម្ពុជាបាន

---

25 *RFI*, 'Ministry of Justice: More than 35,000 criminal cases resolved in 222 days' (*RFI*, 31 December 2020).

26 Lay Saman, 'The Bar Association of Cambodia is committed to expanding the scope of defense for the poor for free' (*Post Khmer*, 10 February 2021).

27 RGC: Ministry of Women's Affairs, 'National Action Plan to Prevent Violence Against Women 2019-2023' (MOWA, October 2020); Ministry of Women's Affairs, 'Neary Rattanak V: Five Year Strategic Plan for Strengthening Gender Mainstreaming and Women's Empowerment 2019-2023' (MOWA, 24 June 2020).

28 Nhum Sokhon, 'Government to continue to protect women's rights so that they can make decisions at all levels, including politics' (*VOD*, 9 March 2021).

29 CCHR, 'Cambodia's Rainbow Families' (CCHR, November 2017) p. 3.

30 UN General Assembly, 'Report of the Working Group on the Universal periodic Review Cambodia', UN Doc. A/HRC/41/17 (5 April 2019).

ប្រកាសថាការអប់រំអ្នកស្រឡាញ់ភេទដូចគ្នានឹងត្រូវបន្ថែមទៅក្នុងកម្មវិធីសិក្សារបស់សាលា នៅឆ្នាំ២០២០ ដើម្បីជួយលុបបំបាត់ការមាក់ងាយ និងការរើសអើងចំពោះសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា[31]។ ទោះយ៉ាងណាក៏ដោយ មិនមានភាពច្បាស់លាស់ទេថាតើកម្មវិធីសិក្សានេះត្រូវបានអនុវត្តពេញលេញហើយឬនៅ។

សមភាពនិងការការពារជនមានពិការភាពមានការរីកចម្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ជាមួយនឹងការបែងចែកផែនការអត្ថប្រយោជន៍សម្រាប់ជនពិការ[32]។ គួរកត់សម្គាល់ថានៅឆ្នាំ ២០២០ រដ្ឋាភិបាលកម្ពុជាបានចេញប្រកាសអន្តរក្រសួងមួយដែលអនុញ្ញាតឱ្យជនមានពិការភាព មានសិទ្ធិទទួលបានប័ណ្ណបើកបរដោយស្របច្បាប់ និងដំណើរការយានយន្តប្រភេទជាក់លាក់ដែលអាចជួយសម្រួលដល់ការរស់នៅ[33]។

*ភាពរីកចម្រើននៃរដ្ឋធម្មនុញ្ញដែលចែងអំពីកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិ*

នៅថ្ងៃទី ២១ ខែកញ្ញាឆ្នាំ ១៩៩៣ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (" រដ្ឋធម្មនុញ្ញ") ត្រូវបានអនុម័តដោយសភាធម្មនុញ្ញដែលបង្កើតឡើងតាមរយៈកិច្ចព្រមព្រៀង ក្នុងមាត្រា១២ នៃកិច្ចព្រមព្រៀង និងព្រះរាជក្រឹត្យរបស់ព្រះមហាក្សត្រនៅថ្ងៃទី ២៤ ខែកញ្ញាឆ្នាំ ១៩៩៣[34]។ ការអនុម័តរដ្ឋធម្មនុញ្ញបាននាំឱ្យមានការបង្កើតជាផ្លូវការនៃរដ្ឋាភិបាលកម្ពុជា បង្កើតប្រទេសកម្ពុជាជារាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញ និងកំណត់ដំណាក់កាលនៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅកម្ពុជា។ តាមស្មារតីនៃកិច្ចព្រមព្រៀង កម្ពុជាប្រកាន់ខ្ជាប់នូវកាតព្វកិច្ចរបស់ខ្លួននិងបានតម្កល់សិទ្ធិមនុស្សផ្សេងៗ នៅក្នុងរដ្ឋធម្មនុញ្ញ រួមមានសិទ្ធិរស់រានមានជីវិតសេរីភាពផ្ទាល់ខ្លួននិងសន្តិសុខ (មាត្រា ៣២) សេរីភាពជាមូលដ្ឋាន (មាត្រា ៣៧, ៤១, ៤២) សេរីភាពខាងសាសនា (មាត្រា ៤៣) និងដំណើរការនីតិវិធីចំពោះមុខច្បាប់ (មាត្រា ៣៨)[35] ។ ជាសំខាន់ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញផ្តល់ឋានៈរដ្ឋធម្មនុញ្ញចំពោះកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជា រួមទាំង ICCPR និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិផ្សេងៗទៀតដែលកម្ពុជាបានផ្តល់សច្ចាប័ន[36]។

---

[31] Matt Blomberg, 'Cambodia to teach LGBT+ issues in schools to tackle discrimination' (*Reuters*, 10 December 2019).

[32] Long Kimmarita, 'Benefit plans in the cards for the disabled population' (*Phnom Penh Post*, 15 June 2020).

[33] Nov, Sivutha, 'Ministries issue prakas allowing disabled to test for driver's licences' (*Phnom Penh Post*, 10 December 2020).

[34] Michelle Brandt, Constitution Assistance in Post-Conflict Countries: The UN Experience: Cambodia, East Timor & Afghanistan' (United Nations Development Program, June 2005).

[35] The Constitution of the Kingdom of Cambodia: available at: https://www.constituteproject.org/constitution/Cambodia_2008?lang=en.

[36] Reaffirmed by the Constitutional Council of the Kingdom of Cambodia Decision No. 092/003/2007, 10 July 2007, p. 2 https://ccc.gov.kh/detail_info_en.php?_txtID=453.

ព្រឹត្តិការណ៍សំខាន់នេះបានផ្តល់នូវក្តីសង្ឃឹមរួមសម្រាប់ពលរដ្ឋកម្ពុជា និងអនាគតនៃសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាន។

ថ្វីបើរដ្ឋធម្មនុញ្ញជាច្បាប់មួយដែលត្រូវបានតាក់តែងយ៉ាងយកចិត្តទុកដាក់ក៏ដោយ ក៏មានការធ្វើវិសោធនកម្មជាច្រើន ដែលចងជាចំណោទពីការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលកម្ពុជាចំពោះកិច្ចព្រមព្រៀងនេះ។ នៅឆ្នាំ ២០១៨ វិសោធនកម្មច្បាប់" ប្រមាថព្រះមហាក្សត្រ" ត្រូវបានបន្ថែមទៅក្នុងរដ្ឋធម្មនុញ្ញដែលមានលក្ខណៈមិនអត់អោនចំពោះអ្នករិះគន់ឬប្រមាថព្រះមហាក្សត្រ និងរឹតត្បិតសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ[37]។ ថ្មីៗនេះ ការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដែលនឹងរារាំងអ្នកដែលមានសញ្ជាតិពីរពីការកាន់តំណែងនយោបាយកំពូលដូចជានាយករដ្ឋមន្ត្រី ប្រធានរដ្ឋសភា ព្រឹទ្ធសភា ឬក្រុមប្រឹក្សាធម្មនុញ្ញដែលជាការរឹតត្បិតសេរីភាពក្នុងការបង្កើតសមាគម[38]។ កាតព្វកិច្ចរបស់កម្ពុជាក្រោមកិច្ចព្រមព្រៀងតម្រូវឱ្យមានការលះបង់ក្នុងនាមរដ្ឋាភិបាលដើម្បីគោរពនិងការពារសិទ្ធិដែលមាននៅក្នុងរដ្ឋធម្មនុញ្ញ។ ការបញ្ចូលសិទ្ធិមនុស្សនៅក្នុងរដ្ឋធម្មនុញ្ញបានបង្ហាញពីការប្តេជ្ញាចិត្តរបស់ រដ្ឋាភិបាលកម្ពុចា ចំពោះកិច្ចព្រមព្រៀងដែលគួរតែបន្តប្រកាន់ខ្ជាប់ដោយគ្មានកំណត់។

## ការដើរថយក្រោយនៃលទ្ធិប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស

ថ្វីបើមានសមិទ្ធផល និងការអភិវឌ្ឍន៍ជាវិជ្ជមានបន្ទាប់ពីការអនុម័តលើកិច្ចព្រមព្រៀងក៏ដោយក៏ប៉ុន្មានឆ្នាំកន្លងមកនេះ មានភាពច្របូកច្របល់ចំពោះសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋាននៅក្នុងប្រទេសកម្ពុជា ហើយសកម្មភាពមួយចំនួនដែលរដ្ឋាភិបាលកម្ពុជាបានរំលោភបំពានលើកិច្ចព្រមព្រៀងនេះ។

### *អតីតគណបក្សប្រឆាំង និងកំសោយនៃការបោះឆ្នោតដោយសេរី និងយុត្តិធម៌*

នៅក្នុងឆ្នាំ២០១៧ ប្រទេសកម្ពុជាបានប្រែក្លាយទៅជារដ្ឋឯកបក្ស បន្ទាប់ពីការរំលាយគណបក្សប្រឆាំងដ៏មានសក្តានុពលគឺគណបក្សសង្គ្រោះជាតិ (គ.ស.ជ) ដោយតុលាការកំពូលនៃព្រះរាជាណាចក្រកម្ពុជា[39]។ មន្ត្រីជាន់ខ្ពស់ជាច្រើននាក់របស់គណបក្សសង្គ្រោះជាតិបានរត់ចេញពីប្រទេស ដែលបច្ចុប្បន្នកំពុងរស់នៅនិរទេសខ្លួននៅក្រៅប្រទេស ខណៈអ្នកផ្សេងទៀតត្រូវបានចាប់ខ្លួន និងជាប់ពន្ធនាគារទៀតផង។ បន្ទាប់ពីការរំលាយមក អាសនៈដែលគណបក្សសង្គ្រោះជាតិបានឈ្នះក្នុងការបោះឆ្នោតថ្នាក់មូល

---

[37] Office of the High Commissioner of Human Rights, 'UN experts say constitutional changes in Cambodia impinge on democracy' (OHCHR, 20 February 2018).

[38] Roseanna Gerin, 'Cambodia's Cabinet Approves Draft Law For Charter Change Aimed at Opposition Leader' (*RFA*, 12 October 2021).

[39] 'Cambodia top court dissolved main opposition CNRP Party' (*BBC*, 16 November 2017).

ដ្ឋានឆ្នាំ២០១៧ ត្រូវបានផ្ទេរទៅឱ្យគណបក្សប្រជាជនកម្ពុជាដែលកំពុងកាន់អំណាចទាំងស្រុង ដែលបង្កឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះភាពខ្វះអ្នកតំណាងផ្នែកនយោបាយ និងការមិនផ្តល់សិទ្ធិផ្តាច់មុខចំពោះពលរដ្ឋខ្មែរមួយផ្នែកធំដែលបានបោះឆ្នោតឱ្យគណបក្សសង្គ្រោះជាតិ[40]។ រដ្ឋាភិបាលកម្ពុជាក៏បានអនុម័តច្បាប់ដែលបង្កនូវបញ្ហាជាច្រើន ដែលធ្វើឱ្យចុះថយនៃជីវភាពនយោបាយ ដែលមានលក្ខណៈជំទាស់សេរីភាពសារព័ត៌មាន និងគណបក្សប្រឆាំង ដោយរួមបញ្ចូលទាំងការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញដែលបានបង្ហាញពីលទ្ធភាពនៃការដកហូតសិទ្ធិចូលរួមក្នុងការបោះឆ្នោត ការរឹតត្បឹតសិទ្ធិបោះឆ្នោត និងព្រមទាំងចាត់វិធានការប្រឆាំងនឹងគណបក្សនយោបាយនានា ដោយមិនចាត់ទុកផលប្រយោជន៍ជាតិជាកត្តាចំបង[41]។

ក្នុងអំឡុងពេលនៃការបោះឆ្នោតឆ្នាំ២០១៨ ការបំភិតបំភ័យ និងការឃោឃីទៅលើអ្នកបោះឆ្នោតជាច្រើនករណីត្រូវបានរាយការណ៍ ជាមួយនឹងការគ្លួញគ្លែរពីគណបក្សប្រឆាំងមួយចំនួនដែលត្រូវបានរារាំង ឬបញ្ឈប់សកម្មភាពឃោសនាការបោះឆ្នោតរបស់ខ្លួន ហើយទៀតសោត អ្នកបោះឆ្នោតប្រឈមនឹងការគំរាមកំហែង[42]។ ការបំភិតបំភ័យនេះបានធ្វើឱ្យប្រទេសជាច្រើន រួមមាន ប្រទេសអូស្ត្រាលី កាណាដា សហរដ្ឋអាមេរិច និងសហភាពអ៊ឺរ៉ុប បានទាញចំណាប់អារម្មណ៍ចំពោះការបោះឆ្នោតនៅកម្ពុជា ហើយពេលនោះដែរអ្នកសង្កេតការណ៍អន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនៅទូទាំងពិភពលោកបានធ្វើការរិះគន់ចំពោះការបោះឆ្នោតនេះថាមិនសេរី យុត្តិធម៌ ក៏ដូចជាមិនតំណាងឱ្យឆន្ទៈរបស់ប្រជាពលរដ្ឋ[43]។

ចាប់តាំងពីឆ្នាំ២០១៨ មក អតីតសមាជិកគណបក្សសង្គ្រោះជាតិ ឬអ្នកគាំទ្រគណបក្សសង្គ្រោះជាតិត្រូវបានគេដាក់ដៅមុខសញ្ញាជាញឹកញាប់ និងមិនឈប់ឈរ ដោយសារតែសម្ព័ន្ធភាពរបស់ពួកគេជាមួយគណបក្សនេះ។ បណ្តាអតីតសមាជិកគណបក្សសង្គ្រោះជាតិ ប្រឈមមុខនឹងការគំរាមកំហែង ការវាយប្រហារលើរាងកាយដោយជនអនាមិក និងការឃោឃីតាមផ្លូវតុលាការផងដែរ[44]។ ជាឧទាហរណ៍ អតីតសមាជិកគណបក្សសង្គ្រោះជាតិជាង ១៣៩ នាក់កំពុងត្រូវបានកោះហៅជាក្រុមធំមួយ ចំពោះការចោទប្រកាន់ដោយគ្មានភស្តុតាងថាអតីតសមាជិកទាំងនេះមានគម្រោងចង់ផ្តួលរំលំរដ្ឋាភិបាល ដោយសារការ

[40] *ABC News*, 'Cambodian opposition rejects election results' (*ABC AU,* 30 July 2013).

[41] CCHR, "Joint Statement: CSOs call for outright rejection of draft amendments to the Constitution and Criminal Code, amid legislative assault on Cambodian peoples' rights and freedoms' (CCHR, 21 February 2018).

[42] RFA, 'UN ExpertDecries Voter Intimidation in Lead-up to Cambodia Election' (*RFA*, 20 July 2018).

[43] Sok Khemara, 'International community condemns Cambodia's elections as a setback to democracy' (*VOA*, 30 July 2018).

[44] CCHR, 'Cambodia Fundamental Freedoms Monitor: Fifth Annual Report, April – December 2020' (CCHR, April 2020).

សម្តែងការគាំទ្រចំពោះការប៉ុនប៉ងរបស់លោកសមរង្ស៊ីវិលត្រឡប់មកកម្ពុជានៅឆ្នាំ២០១៩ ដោយអតីតសមាជិកខ្លះត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេល ២៥ ឆ្នាំរួចទៅហើយ[45]។

ជាមួយនឹងការបោះឆ្នោតជាតិដែលនឹងមកដល់នៅឆ្នាំ២០២២ មានមនុស្សជាច្រើនបានចោទសួរអំពីសុចរិតភាពនៃដំណើរការបោះឆ្នោត និងថាតើព្រឹត្តិការណ៍នៃឆ្នាំ២០១៨ អាចនឹងកើតឡើងម្តងទៀតដែរឬទេ។ កាលពីខែកញ្ញា ឆ្នាំ២០២១ សមាជិកនៃគណបក្សនយោបាយដែលទើបបង្កើតថ្មី គឺគណបក្សខ្មែរស្រឡាញ់ជាតិ បានរាយការណ៍ពីការត្រួតពិនិត្យហួសហេតុពីសំណាក់អាជ្ញាធរ នៅពេលខ្លួនប៉ុនប៉ងធ្វើសកម្មភាពគណបក្ស ជាមួយគ្នានេះអាជ្ញាធរថែមទាំងហាមឃាត់ និងគំរាមកំហែងខ្លួនពីការព្យួរបដារបស់គណបក្សមុនការបោះឆ្នោតមកដល់[46]។ ការបន្តដៅមុខសញ្ញាចំពោះគណបក្សប្រឆាំង គឺមិនមានអំណោយផលអ្វីដល់សង្គមប្រជាធិបតេយ្យ តែផ្ទុយនឹងកិច្ចព្រមព្រៀងនៃទីក្រុងប៉ារីសទាំងស្រុង។

*ការកំណត់គោលដៅទៅលើសកម្មជនចំពោះការអនុវត្តសេរីភាពជាមូលដ្ឋាន*

លទ្ធភាពក្នុងការអនុវត្តសេរីភាពជាមូលដ្ឋានក៏បានចុះខ្សោយផងដែរ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ លំហសង្គមស៊ីវិលគឺមិនមានសេរីភាពនោះទេសម្រាប់អ្នកដែលចង់អនុវត្តសេរីភាពជាមូលដ្ឋានរបស់ខ្លួន ដោយរដ្ឋាភិបាលមិនពេញចិត្ត ឬមើលឃើញថាការអនុវត្តសេរីភាពជាមូលដ្ឋានជាការរិះគន់ទៅលើវិធីសាស្ត្រនៃអភិបាលកិច្ចរបស់ខ្លួន។ ចាប់ពីខែមេសា ឆ្នាំ២០១៩ ដល់ខែធ្នូ ឆ្នាំ២០២០ គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋានរបស់ ម.ស.ម.ក បានកត់ត្រាការរំលោភបំពានចំនួន ២២០ និងការរឹតបន្តឹងចំនួន ៧៤ នៃសេរីភាពមូលដ្ឋាននៅក្នុងប្រទេស[47]។ បុគ្គលរាប់មិនអស់បានទទួលរងការដកហូតសេរីភាពរបស់ខ្លួនដោយសារតែការចាប់ខ្លួន និងការជាប់ពន្ធនាគារ ដោយសារតែការចូលរួមរបស់ខ្លួន គឺជាសកម្មភាពចាំបាច់ និងមានសារៈសំខាន់ក្នុងការអនុវត្តសេរីភាពជាមូលដ្ឋាន។ ឧទាហរណ៍ លោក គង់ រ៉ៃយ៉ា អតីតសកម្មជនយុវជនគណបក្សសង្គ្រោះជាតិ ត្រូវបានចាប់ខ្លួន ផ្តន្ទាទោស និងដាក់ពន្ធនាគារចំនួនពីរដងពីបទចោទប្រកាន់ពាក់ព័ន្ធនឹងរឿងនយោបាយ។ ដោយករណីមួយ លោក គង់ រ៉ៃយ៉ា ត្រូវបានគេកំណត់គោលដៅលើការបង្ហោះតាមហ្វេសប៊ុក (Facebook) ដែលគេចោទថាបានអំពាវនាវឱ្យមាន "បដិវត្តន៍ពណ៌" នៅក្នុងប្រទេសកម្ពុជា ហើយករណីមួយទៀត គាត់ត្រូវបានគេកំណត់គោលដៅរឿងផ្សព្វផ្សាយអាវយឺតលើហ្វេសប៊ុក (Facebook) ដែលមានរូប និងទស្សនៈរបស់អ្នកវិភាគលោក កែម ឡី ដែលត្រូវបានគេសម្លាប់។

---

[45] Seng Thai, 'Updated CNRP Leaders Lose Right to Stand for Office, Get 20-25 Year Sentences', (*VOD*, 2 March 2021).

[46] Kohsuntepheap, 'Senior Khmer Patriot Party official says authorities will not allow party signs to be erected' (Kohsentepheap, 8 September 2021).

[47] CCHR, 'Cambodia Fundamental Freedoms Monitor: Fifth Annual Report, April – December 2020' (CCHR, April 2020) p. 15.

ក្រោយពីរួចផុតពីការជាប់ពន្ធនាគារជាលើកទី២ ជនអនាមិកបានប្រើហិង្សាទៅលើលោក គង់ រ៉ៃយ៉ា ពេលកំពុងជិះម៉ូតូបណ្តាលឱ្យរងរបួសធ្ងន់ផងដែរ។ ប៉ុន្មានខែក្រោយមក លោក គង់ រ៉ៃយ៉ា បានប្រកាសចូលនិវត្តន៍ពីភាពសកម្មរបស់ខ្លួន ដោយសារតែការព្រួយបារម្ភយ៉ាងខ្លាំងចំពោះសុវត្ថិភាពផ្ទាល់ខ្លួន[48]។

លោកគង់ រ៉ៃយ៉ា មិនមែនជាសកម្មជនតែម្នាក់គត់ដែលប្រឈមមុខនឹងដាក់គោលដៅមិនឈប់ឈរបែបនេះទេ។ លោក រ៉ុង ឈុន ប្រធានសហភាពសហជីពកម្ពុជា និងជាសកម្មជននយោបាយ និងសិទ្ធិមនុស្សដ៏លេចធ្លោម្នាក់ ត្រូវបានចាប់ខ្លួនកាលពីខែកក្កដា ឆ្នាំ២០២០ ដោយចោទប្រកាន់ពីបទញុះញង់ និងផ្សព្វផ្សាយព័ត៌មានក្លែងក្លាយ ដោយសារតែលោកបានបង្ហោះតាមហ្វេសប៊ុកអំពីការបោះបង្គោលព្រំដែន នៅព្រំដែនកម្ពុជា-វៀតណាម ដែលលោកអះអាងថា កម្ពុជាបានប្រគល់ដីទៅឱ្យវៀតណាម។ លោកត្រូវបានបង្ខំឱ្យស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នរយៈពេលជិត ១៣ខែ មុនពេលដែលលោកត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគារអតិបរមាចំនួន ២ឆ្នាំ[49]។ បន្ថែមពីនេះ សកម្មជនបរិស្ថានបីនាក់មកពីបណ្តាញមាតាធម្មជាតិ ត្រូវបានចាប់ខ្លួន និងកាត់ទោសពីបទរៀបចំផែនការដើរដង្ហែក្បួនដោយស្ត្រីម្នាក់ ដើម្បីផ្សព្វផ្សាយអំពីបញ្ហាបរិស្ថាន[50]។ ក្នុងពេលកំពុងជាប់ពន្ធនាគារសកម្មជនបរិស្ថានទាំងបីនាក់នេះត្រូវបានប្រឈមភ្លាមៗដោយការចោទប្រកាន់បន្ថែមពីបទឃុបឃិត និងសមគំនិត ហើយឥឡូវនេះត្រូវប្រឈមនឹងការជាប់ពន្ធនាគាររហូតទៅដល់១០ឆ្នាំ[51]។

*លក្ខខណ្ឌពន្ធនាគារ ដកហូតសិទ្ធិរស់នៅ និងសេរីភាពរបស់អ្នកទោស*

ប្រទេសកម្ពុជាត្រូវបានគេដឹងថាមានអត្រាអ្នកជាប់ឃុំខ្ពស់ និងលក្ខខណ្ឌពន្ធនាគារគួរឲ្យអាសូរ ដោយមានអត្រាអ្នកជាប់ឃុំខ្ពស់លើសចំណុះរហូតទៅដល់ ៣០០%[52]។ ភាពចង្អៀតណែន និងការជាប់ឃុំឃាំងហួសកំណត់ ធ្វើឱ្យអ្នកទោសទទួលរងការឈឺចាប់ធ្ងន់ធ្ងរ រងសម្ពាធទាំងផ្លូវចិត្ត និងផ្លូវកាយ និងប្រឈមនឹងហានិភ័យពីការធ្វើទារុណកម្ម និងការរំលោភបំពានផងដែរ។ ក្រៅពីមានភាពចង្អៀតណែន ស្ថានភាពនៅក្នុងពន្ធនាគារក៏មិនមានភាពល្អប្រសើរដែលឆ្លើយតបនឹងតម្រូវការជាមូលដ្ឋាន ដូចជាការទទួលបានអាហារ និងទឹកស្អាត ដែលជារឿយៗតែងតែកើតមានឡើងចំពោះបុគ្គលជាប់ឃុំដែលមិនមានលទ្ធភាពទិញ[53]។ ច្បាប់កម្ពុជាក៏មិនបានផ្តល់នូវការធានាចំពោះការទទួលបានការថែទាំសុខភាពសម្រាប់

48 Tran Techseng, 'Twice Jailed, Thrice Shy: Kung Raiya Ends Activism Over Safety Fears' (*VOD*, 14 July 2021).

49 Ouch Sony, "Updated: Rong Chhun Sentenced to Two Years in Jail for Vietnam Comments," (*VOD*, August 18 21).

50 Khan Leakena, 'Phnom Penh authorities send 3 young mothers to court' (*VOD*, 4 September 2020).

51 Khy Sovuthy, 'Three convicted Mother Nature activists handed an additional plotting charge' (*Camboja* , 21 July 2021).

52 UN Human Rights Council, 'Situation of human rights in Cambodia: Report of the Special Rapporteur on the situation of human rights in Cambodia', A/HRC/45/51, 24 August 2020 para 41.

53 LICADHO, 'Life in Prison: A Mother's Story' (LICADHO, 2 December 2019).

អ្នកជាប់ឃុំផងដែរ[54]។ ដូចជាបុគ្គលដែលឈឺ ឬស្ត្រីមានផ្ទៃពោះដែលកំពុងជាប់ឃុំឃាំង ជារឿយៗមិនត្រូវបានព្យាបាលដោយអ្នកជំនាញវេជ្ជសាស្ត្រនោះទេ ដែលបណ្ដាលឱ្យមានការប្រឈមដល់អាយុជីវិត រួមទាំងទារក ឬកុមារតូចៗផងដែរ[55]។

## *ការបណ្ដេញចេញដោយបង្ខំជាមួយនឹងសំណងមិនសមរម្យ*

ការបណ្ដេញចេញដោយបង្ខំ បានកើតមានជាទូទៅនៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាងមួយទស្សវត្សរ៍មកហើយ ប៉ុន្តែកាន់តែធ្ងន់ធ្ងរនោះ ស្ថានភាពជំងឺកូវីដ-១៩ នៅក្នុងប្រទេសនេះបានបង្កើតឱកាសយ៉ាងលើសលប់ ចំពោះការបណ្ដេញចេញដោយបង្ខំដោយមានអត្រាកើនឡើងយ៉ាងកំហុក ព្រមទាំងការព្រងើយកន្តើយចំពោះសិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋដែលត្រូវបានបណ្ដេញចេញ។ ប្រជាជនកម្ពុជារាប់ពាន់នាក់ត្រូវបានបណ្ដេញចេញពីទឹកដីរបស់ខ្លួន ដែលផ្ដល់ប្រភពចំណូលដ៏សំខាន់ ស្ថិរភាព និងសុវត្ថិភាពដើម្បីត្រួសត្រាយផ្លូវសម្រាប់គម្រោងអភិវឌ្ឍន៍ឯកជនក្នុងការរកប្រាក់ចំនេញ។ អ្នកស្រុកដែលត្រូវបានបណ្ដេញចេញកម្រនឹងផ្ដល់សំណងសម្រាប់ការបាត់បង់ប្រភពចំណូលតែមួយគត់របស់ខ្លួនណាស់។ ក្នុងករណីដែលពួកគេត្រូវបានផ្ដល់សំណង គឺមានចំនួនតិចតួចបំផុតដែលផ្ដល់ជូនដោយមិនគ្រប់គ្រាន់ដើម្បីទិញដីនៅកន្លែងផ្សេងទៀតបាននោះទេ ដោយធ្វើឱ្យពលរដ្ឋរាប់រយនាក់ធ្លាក់ក្នុងស្ថានភាពក្រីក្រយ៉ាងធ្ងន់ធ្ងរ។ ខណៈពេលដែលអ្នកភូមិដែលទទួលរងគ្រោះដោយសារតែការបណ្ដេញចេញជាច្រើនព្យាយាមតវ៉ានឹងភាពអយុត្តិធម៌ទាំងនេះ និងដើម្បីទាមទារសំណងសមរម្យ គឺតែងតែត្រូវបានគេព្រងើយកន្តើយ គំរាមកំហែង ចាប់ខ្លួន ជុំវិញសកម្មភាពរបស់ខ្លួន ឬទទួលរងសម្ពាធពីអាជ្ញាធរឱ្យទទួលយកសំណងមិនសមរម្យដោយមិនឆ្លើយតបនឹងការចង់បានរបស់ខ្លួនផងដែរ[56]។

## *កង្វះស្ថាប័នឯករាជ្យ*

ឯករាជ្យភាពរបស់តុលាការកម្ពុជា ត្រូវបានគេរិះគន់ជាយូរណាស់មកហើយ ខណៈដែលអ្នកការពារសិទ្ធិមនុស្ស សកម្មជន និងអ្នកនយោបាយដែលមាននិន្នាការប្រឆាំង បានទទួលរងការកាត់ទោសព្រហ្មទណ្ឌយ៉ាងធ្ងន់ធ្ងរ ដោយមានភស្តុតាងតិចតួចបំផុតថាអ្នកទាំងអស់នោះបានប្រព្រឹត្តបទឧក្រិដ្ឋដូចដែលអាជ្ញាធរបានអះអាង។ ករណីមួយដែលកើតឡើងនៅខែកញ្ញា ឆ្នាំ២០២១ នៅពេលដែលរដ្ឋមន្ត្រីក្រសួងការពារជាតិ ណែនាំអាជ្ញាធរមូលដ្ឋានឱ្យចាត់វិធានការតាមផ្លូវច្បាប់លើអ្នកកាសែតម្នាក់ឈ្មោះ យួន ឈីវ បន្ទាប់ពីរូបលោកបានបង្ហោះហ្វេសប៊ុកដោយបានរិះគន់អាជ្ញាធរចំពោះចំណាត់ការជម្លោះដីធ្លីមួយកន្លែង

---

[54] LICADHO, 'Torture and Ill-Treatment: Testimony from inside Cambodia's police stations and prisons' (LICADHO, June 2014), p. 18.

[55] Erin Handley, 'Cambodia's drug war has seen prisoner numbers skyrocket during coronavirus pandemic' (*ABC AU*, 30 May 2020); Lay Sopheavathy, 'Land Dispute: Inmate Dies During Hospital Treatment' (*Thmey Thmey*, 7 September 2021).

[56] CCHR, 'Factsheet: Forced Evictions in Cambodia during COVID-19' (CCHR, October 2021).

ដោយការបណ្ដេញ និងបំផ្លាញដំណាំរបស់ប្រជាពលរដ្ឋ។ ក្រោយមកលោក ឈឺវ ត្រូវបានចាប់ទៅឃុំខ្លួនដើម្បីសាកសួរ ហើយក្នុងរយៈពេលតែមួយថ្ងៃត្រូវបានចោទប្រកាន់ ផ្ដន្ទាទោស និងកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេល ១ឆ្នាំ[57]។

ការប្រើប្រាស់ប្រព័ន្ធតុលាការនេះគឺអាចធ្វើទៅបានតាមរយៈច្បាប់ជាមូលដ្ឋានចំនួនបីដែលមានគោលបំណងធានានូវឯករាជ្យភាពរបស់តុលាការ[58] ប៉ុន្តែផ្ទុយទៅវិញ បានផ្ដល់ការគ្រប់គ្រងដោយផ្ទាល់លើប្រព័ន្ធតុលាការប្រកបដោយប្រសិទ្ធភាពតាមរយៈអំណាចធន្ទានុសិទ្ធិជាមួយនឹងគម្រោងថវិការបស់តុលាការ ការតែងតាំង ការដំឡើងឋានៈ តួនាទី និង ការដកយកចេញជាដើម[59]។

## សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

បើទោះបីជាមានសមិទ្ធិផលល្អប្រសើរ ចាប់តាំងពីការចុះហត្ថលេខាលើកិច្ចព្រមព្រៀងក៏ដោយ ក៏ទិដ្ឋភាពសិទ្ធិមនុស្សក្នុងប្រទេសកម្ពុជានៅតែបន្តធ្លាក់ចុះ ដែលជាហេតុគួរឱ្យព្រួយបារម្ភយ៉ាងខ្លាំង។ កាលពី៣០ឆ្នាំ មុន បើទោះជាមានការរីកចម្រើននៃដំណើរការលទ្ធិប្រជាធិបតេយ្យ និងការលើកកម្ពស់សិទ្ធិមនុស្សត្រូវបានពង្រឹងនៅពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងក៏ដោយ ប៉ុន្តែសិទ្ធិសម្រាប់ប្រជាជនកម្ពុជាហាក់ដូចជាត្រូវបានធានាតែលើក្រដាសជាជាងការអនុវត្តជាក់ស្ដែង។ កិច្ចព្រមព្រៀងគឺជាឯកសារយូរអង្វែង និងជាកិច្ចព្រមព្រៀង ដែលជំរុញឱ្យមានសមិទ្ធិផលដ៏ប្រសើរមួយនៃសតវត្សទី២០ ដោយបង្កើតនូវទស្សនវិស័យ ព្រមទាំងបំផុសនូវគំនិត ថាប្រទេសណាក៏អាចសម្រេចបានសន្តិភាព និងលទ្ធិប្រជាធិបតេយ្យជាមួយនឹងសិទ្ធិមនុស្ស ព្រមទាំងសេរីភាពជាមូលដ្ឋានជារឿងចាំបាច់ផងដែរ។ កិច្ចព្រមព្រៀងទាមទារឱ្យមានការយកចិត្តទុកដាក់ជាពិសេសក្នុងការរក្សា និងការពារសិទ្ធិ និងកាតព្វកិច្ចដែលបានកំណត់។ កិច្ចខិតខំប្រឹងប្រែងរួម គឺមានភាពចាំបាច់ពីគ្រប់ភាគីពាក់ព័ន្ធដើម្បីចាត់វិធានការបន្ទាន់ និងការប្ដេជ្ញាចិត្តជាថ្មីដើម្បីគោរពកិច្ចព្រមព្រៀង។ រហូតទាល់តែមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាបែបនេះ ទើបសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យនឹងមិនបន្តមានភាពផុយស្រួយក្នុងប្រទេសកម្ពុជា។ ដូច្នេះ ម.ស.ម.ក សូមផ្ដល់ជូននូវអនុសាសន៍ចំពោះភាគីពាក់ព័ន្ធមានដូចខាងក្រោមក្នុងការចាត់វិធានការចាំបាច់ដើម្បីផ្សះផ្សាការខ្វះខាតនៃការអនុលោមតាមផ្នែកខ្លះនៃកិច្ចព្រមព្រៀង៖

## ចំពោះរាជរដ្ឋាភិបាលកម្ពុជា

---

[57] Khoun Narim, 'Digital news publisher convicted, sentenced to prison for Koh Kong dispute' (*Camboja*, 30 September 2021).

[58] The *Law on the Organization of the Court* is available at: https://www.arbitrationcouncil.org/download/law-on-the-organization-of-courts/; The *Law on the Statute of Judges and Prosecutors* is available at: https://www.arbitrationcouncil.org/download/law-on-the-status-of-judges-and-prosecutors/; The *Law on the Organization and Function of the Supreme Council of Magistracy* is available at: https://www.arbitrationcouncil.org/download/law-on-the-organization-and-functioning-of-supreme-council-of-magistracy/.

[59] CCHR, Destination Justice and ADHOC, 'Joint Submission to the Human Rights Council of the United Nations Third Universal Periodic Review of the Kingdom of Cambodia, Access to Justice in Cambodia' (12 July 2018) Section 2 www.ohchr.org/EN/HRBodies/UPR/Pages/UPRKHStakeholdersInfoS32.aspx.

១.សូមប្រកាន់ខ្ជាប់នូវកាតព្វកិច្ចរបស់ខ្លួនចំពោះកិច្ចព្រមព្រៀង និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដោយផ្តល់អាទិភាពដល់ការលើកកម្ពស់ និងការការពារសេរីភាពជាមូលដ្ឋាន និងសិទ្ធិមនុស្ស។
២.សូមបញ្ឈប់រាល់ការយាយីទៅលើអ្នកនយោបាយដែលមាននិន្នាការប្រឆាំង អ្នកការពារសិទ្ធិមនុស្ស អ្នកសារព័ត៌មានឯករាជ្យ និងតួអង្គសង្គមស៊ីវិល ជាពិសេស សូមបញ្ឈប់រាល់ការចោទប្រកាន់ក្រោមហេតុផលនយោបាយ។ និង
៣. ដោះលែងជាបន្ទាន់រាល់អ្នកទោសមនសិការទាំងអស់ និងអ្នកទោសដែលត្រូវបានឃុំខ្លួនតាមអំពើចិត្ត ដែលបណ្តាលមកពីការអនុវត្តដោយអហិង្សា និងស្របច្បាប់ចំពោះសេរីភាពជាមូលដ្ឋានរបស់ខ្លួន។

<u>**ចំពោះរដ្ឋហត្ថលេខីនៃកិច្ចព្រមព្រៀង**</u>

១. ក្នុងនាមខ្លួនជាសមាជិកនៃអង្គការអន្តររដ្ឋាភិបាល ជាពិសេសអង្គការសហប្រជាជាតិ សូមឆ្លៀតឱកាសបង្កើនការយល់ដឹងអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា និងជំរុញឱ្យរដ្ឋាភិបាលកម្ពុជាបញ្ឈប់ ឬដោះស្រាយបញ្ហារំលោភបំពាននានា។
២. ដូចដែលមានចែងក្នុងមាត្រា ៥ (៤) នៃកិច្ចព្រមព្រៀងស្តីពីអធិបតេយ្យភាព ឯករាជ្យភាព បូរណភាពទឹកដី ភាពមិនអាចរំលោភបំពានបាន អព្យាក្រឹត្រភាព និងឯកភាពជាតិ នៃកម្ពុជា ក្នុងករណីបើមានការរំលោភសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា សូមអំពាវនាវដល់ស្ថាប័នមានសមត្ថកិច្ចរបស់អង្គការសហប្រជាជាតិឱ្យមានវិធានការដោះស្រាយ។ និង
៣. នៅក្នុងការចាប់ផ្តើមនៃការវិនិយោគថ្មី សន្ធិសញ្ញា ឬជំនួយអភិវឌ្ឍន៍ សូមពិចារណានូវលទ្ធភាពក្នុងការបង្កើនទំនាក់ទំនងទាំងនេះ ដើម្បីលើកកម្ពស់សិទ្ធិមនុស្សនៅកម្ពុជា។

<u>**ចំពោះអង្គការសហប្រជាជាតិ**</u>

១. អគ្គលេខាធិការអង្គការសហប្រជាជាតិ គួរជំរុញអំណាចរបស់ខ្លួននៅក្រោមកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះកម្ពុជា មាត្រា ២៩ ដើម្បីធ្វើការពិគ្រោះយោបល់សមស្របណាមួយជាមួយសមាជិកនៃសន្និសីទប៉ារីសស្តីពីកម្ពុជា ដើម្បីធានាថារដ្ឋាភិបាលកម្ពុជា កំពុងគោរពការប្តេជ្ញាចិត្តរបស់ខ្លួនក្រោមកិច្ចព្រមព្រៀងនេះ។ និង
២. ចំពោះអ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា គួររក្សាការសន្ទនាដោយស្មោះត្រង់ និងបើកចំហជាមួយរដ្ឋាភិបាលកម្ពុជា ដោយផ្តល់នូវអនុសាសន៍សមស្របសម្រាប់ការធ្វើឱ្យប្រសើរឡើងនៃការការពារសិទ្ធិមនុស្សនៅកម្ពុជា។ ហើយក្នុងករណីចាំបាច់ ដើម្បីផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេស ដើម្បីដោះស្រាយគោលនយោបាយ ច្បាប់ ឬសកម្មភាពដែលមានឥទ្ធិពលដល់ការគាបសង្កត់ទៅលើសិទ្ធិមនុស្ស។

**<u>ចំពោះអង្គការសង្គមស៊ីវិល</u>**

១. សូមមានភាពអត់ធន់ និងបន្តធ្វើសកម្មភាពជាសមូហភាពក្នុងការអ្នកឃ្លាំមើល ដើម្បីផ្សព្វផ្សាយការរំលោភសិទ្ធិមនុស្សនៅកម្ពុជា និងបញ្ឈប់រដ្ឋាភិបាលកម្ពុជាលើការរំលោភបំពាននេះ។

២.ចូលរួមជាមួយយន្តការរបស់អង្គការសហប្រជាជាតិ ជាពិសេសក្រុមប្រឹក្សាសិទ្ធិមនុស្ស និងដំណើការត្រួតពិនិត្យជាសកលតាមកាលកំណត់ជាដើម តាមរយៈការអំពាវនាវឱ្យមានធាតុចូល ឬរបាយការណ៍ត្រួតពិនិត្យ ដើម្បីបង្ហាញពីការរំលោភសិទ្ធិមនុស្ស។ និង

៣. គាំទ្រ និងពង្រឹងអំណាចដល់សហគមន៍ដើម្បីទាមទារសិទ្ធិរបស់ខ្លួន។

ប្រសិនបើលោកអ្នកមានចម្ងល់ ឬត្រូវការព័ត៌មានបន្ថែម ឬប្រសិនបើអ្នកចង់ផ្តល់មតិកែលម្អ សូមផ្ញើអ៊ីមែលមកនាយិកាប្រតិបត្តិរបស់ម.ស.ម.ក អ្នកស្រី ចក់ សុភាព តាមរយៈ chaksopheap@cchrcambodia.org ។ ម្យ៉ាងទៀតសូមទាក់ទងមកតាមលេខរយៈ +៨៥៥(០)២៣ ៧២ ៦៩ ០១ ឬទាក់ទងមកផ្ទះលេខ ៧៩៨ ផ្លូវ ៩៩ សង្កាត់បឹងត្របែក ខណ្ឌចម្ការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា។